# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត**

មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាស្ថាប័នស្រាវជ្រាវស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) បង្កើតឡើងតាំងពីឆ្នាំ១៩៩៥ ក្នុងគោលបំណងថែរក្សាការចងចាំនិងស្វែងរកយុត្តិធម៌ ជូនជនរងគ្រោះនៃរបបខ្មែរក្រហម។ គោលបំណងទាំងពីរនេះ គឺជាមូលដ្ឋាននៃការផ្សះផ្សារបួសផ្លូវចិត្ត និងការពារកុំឲ្យរបបខ្មែរក្រហមកើតឡើងជាថ្មីម្តងទៀត។ ខណៈដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសម្រេចគោលបំណងទាំងនេះ តម្លាភាពនិងគណនេយ្យភាពចូលរួមចំណែកយ៉ាងសំខាន់ក្នុងបេសកកម្មនេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន ២រូប ដើម្បីបម្រើការងារជាជំនួយការគណនេយ្យ។

លក្ខខណ្ឌការងារ ៖

- គណនានិងត្រួតពិនិត្យមើលការចំណាយ ចំនួនទឹកប្រាក់ចំណាយ និងកំណត់ត្រាឱ្យមានភាពត្រឹមត្រូវ
- ត្រួតពិនិត្យមើលឯកសារចំណាយនិងឯកសារយោងផ្សេងៗប្រចាំខែ
- ត្រួតពិនិត្យមើលបញ្ជីសារពើភ័ណ្ឌនិងសម្ភារការិយាល័យជាប្រចាំ
- រៀបចំបញ្ជី spreadsheet សៀវភៅធំ ទាក់ទងនឹងការទិញ លក់ និងសៀវភៅទិន្នានុប្បវត្តន៍
- ធ្វើការងារផ្សេងៗទៀតដែលស្នើឡើងដោយ មន្ត្រីគ្រប់គ្រងគម្រោងថវិកា នាយករង និងនាយកប្រតិបត្តិ

*សូមបញ្ជាក់ថា ៖ បេក្ខជនដែលត្រូវបានជ្រើសរើសមកធ្វើការងារស្ម័គ្រចិត្តនឹងទទួលបានការបណ្តុះបណ្តាលមុននឹងចាប់ផ្តើមធ្វើការងារខាងលើ។*

លក្ខខណ្ឌជ្រើសរើស ៖

- និស្សិតទើបបញ្ចប់ការសិក្សា ឬកំពុងសិក្សាឆ្នាំទី៣ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ ឬធនាគារ
- មានចិត្តស្មោះត្រង់និងអំណត់ក្នុងការងារ
- មានគំនិតទទួលយកចំណេះដឹងថ្មីៗ និងមានភាពច្នៃប្រឌិត
- មានបំណងបន្តការសិក្សាថ្នាក់អនុបណ្ឌិត ឬសញ្ញាប័ត្រជាន់ខ្ពស់នៅបរទេស
- មានចំណេះដឹងភាសាអង់គ្លេស អាចសរសេរនិងនិយាយបានខ្លះ
- ចេះប្រើកុំព្យូទ័រ និងកម្មវិធី word និង excel

ប្រសិនបើនិស្សិតចាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តខាងលើ សូមផ្ញើប្រវត្តិរូប (CV) និងលិខិតបញ្ជាក់ពីចំណាប់អារម្មណ៍មក សូ ហ្វារីណា តាមរយៈអ៊ីម៉ែល truthfarina.s@dccam.org ឬ ទាក់ទងតាមទូរស័ព្ទលេខ ០១២ ៥៨៦ ២៩៣

**ផុតកំណត់ទទួលពាក្យនៅថ្ងៃទី១៣ខែសីហាឆ្នាំ២០១៧។**